មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# អត្ថបទសង្ខេបនៃការវិភាគផ្លូវច្បាប់ លើការចោទប្រកាន់ និងការផ្តន្ទាទោស លើអ្នកសារព័ត៌មាន និងសកម្មជនការពារសិទ្ធិមនុស្សគឺលោក ម៉ម សូណង់ដូ (សំណុំរឿងព្រហ្មទណ្ឌ លេខ២២០៧)

## ១. សាវតារ

នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ លោកម៉ម សូណង់ដូ ("ជនជាប់ចោទ") ដែលជាម្ចាស់វិទ្យុសំបុកឃ្មុំ និងជាប្រធានអង្គការមិនមែនរដ្ឋាភិបាលដ៏ល្បី ("អ.ម.រ") ដែលហៅថា សមាគមអ្នកប្រជាធិបតេយ្យ ត្រូវបានតុលាការរកឃើញពិរុទ្ធភាពពីបទចោទប្រកាន់ចំនួន៦ករណី ("បទចោទប្រកាន់") តាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ("ក្រមព្រហ្មទណ្ឌ") បន្ទាប់ពីសវនាការជំនុំជម្រះរយៈពេល៤ថ្ងៃ នៅសាលាដំបូងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១១ ដល់១៤ ខែកញ្ញា ឆ្នាំ២០១២ ជាសរុបហៅថា ("ការជំនុំជម្រះ")។ បទចោទប្រកាន់មានដូចជា៖ មាត្រា៤៥៦ និង៤៥៧ ដែលហាមមិនឲ្យមានការធ្វើកុបកម្ម និងចែងពីទោសដែលភ្ជាប់មកជាមួយ, មាត្រា៤៦៤ ដែលហាមមិនឲ្យញុះញង់ប្រជាពលរដ្ឋកាន់អាវុធប្រឆាំងអាជ្ញាធរស្របច្បាប់, មាត្រា៥០៤ ដែលហាមឃាត់មិនឲ្យមានការប្រឆាំងនឹងអ្នករាជការសាធារណៈ,មាត្រា៦០៩ ដែលហាមមិនឲ្យមានការជ្រៀតជ្រែកដោយខុសច្បាប់ក្នុងការបំពេញមុខងារសាធារណៈ, និងមាត្រា២៨ ដែលចែងពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬក៏បទមជ្ឈិមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ជាលទ្ធផល ជនជាប់ចោទត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ និងពិន័យជាប្រាក់១០លានរៀល។ យោងតាមមាត្រា៣៨២ នៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ជនជាប់ចោទទាំងឡាយ មានពេលមួយខែដើម្បីប្តឹងជំទាស់ទៅនឹងសាលក្រមផ្តន្ទាទោសលើខ្លួន។ ជនជាប់ចោទបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ សាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍នោះ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ហើយសវនាការលើបណ្តឹងឧទ្ធរណ៍នឹងត្រូវធ្វើឡើងនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣។ រាល់កាលបរិច្ឆេទ និងហេតុការណ៍ដែលពាក់ព័ន្ធទាំងអស់ ត្រូវបានដាក់បញ្ចូលក្នុងកាលប្បវត្តិនៃព្រឹត្តិការណ៍ ដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធរបស់អត្ថបទសង្ខេបនេះ។

បទចោទប្រកាន់ជាប់ពាក់ព័ន្ធជាច្រើននឹងព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ក្នុងរយៈពេលពីរបីខែដើមឆ្នាំ២០១២។ ក្រុមហ៊ុនឯកជនដែលជាកម្ម–សិទ្ធិរបស់ជនជាតិរុស្ស៊ីដ៏មានឥទ្ធិពលមួយ ឈ្មោះថា កាសូទីម ខូអ៊ិលធីឌី ("កាសូទីម") បានទទួលសម្បទានដីព្រៃ នៅក្នុងតំបន់នោះកាលពីឆ្នាំ១៩៩៦ ហើយដីទំហំ១៥.000ហិកតានៃដីសម្បទាននោះបានទន្ទ្រានភូមិប្រម៉ា ដែលបង្កើតឲ្យមានទំនាស់ដីធ្លីជាមួយប្រជាកសិករប្រហែល១.០០០គ្រួសារ ហើយក្រុមគ្រួសារមកពីភូមិនោះ

("អ្នកភូមិ") ក៏បានអះអាងពីកម្មសិទ្ធិលើដីនោះផងដែរ។ ជាការឆ្លើយតប អ្នកភូមិត្រូវបានរាយការណ៍ថាបានរៀបចំ និងកេណ្ឌគ្នីគ្នា ដើម្បីការពារដីធ្លី និងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ព្រមទាំងដើម្បីប្រឆាំងនឹងការទន្ទ្រានពីសំណាក់ក្រុមហ៊ុន កាសូទីម។ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ ទាហាន កងរាជអាវុធហត្ថ និងនគរបាលមូលដ្ឋានរាប់រយនាក់ប្រដាប់ដោយអាវុធ បានឆ្មក់ចូលក្នុងភូមិប្រម៉ា ដោយថែមទាំងមានជំនួយពីឧទ្ធម្ភាគចក្រយោធាមួយគ្រឿង ដែលសម្តែងយ៉ាងច្បាស់ពីការប៉ុនប៉ងមួយដើម្បីបំបែកការប្រឆាំងតវ៉ារបស់អ្នកភូមិ និងដើម្បីជម្លៀសអ្នកភូមិចេញពីតំបន់ដែលប៉ះពាល់នោះ។ ទាហាន និងនគរបាលបានប្រើប្រាស់នូវកម្លាំងពុំសមាមាត្រប្រឆាំងនឹងអ្នកភូមិ ដែលបានបណ្តាលឲ្យមានមរណៈភាពដល់ក្មេងស្រីអាយុ១៤ឆ្នាំម្នាក់ ឈ្មោះ ហេង ចន្ថា ដែលត្រូវបានបាញ់សម្លាប់ខណៈដែលរូបនាង និងគ្រួសារកំពុងតែពួនសម្ងំពីការអន្តរាគមន៍ដោយប្រើអាវុធ។ បន្ទាប់ពីព្រឹត្តិការណ៍នោះ អាជ្ញាធរបានអះអាងថា អ្នកភូមិទទួលខុសត្រូវចំពោះការប៉ុនប៉ងបង្កើតចលនាអបគមន៍ ដើម្បីផ្តាច់ខ្លួនចេញប្រទេសកម្ពុជា ហើយបង្កើតជា រដ្ឋក្នុងរដ្ឋ ("អបគមន៍") ដែលមានលក្ខណៈស្វ័យភាព។ ព្រឹត្តិការណ៍នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១២ នឹងសំដៅចំពោះ "ឧបទ្ទវហេតុនៅភូមិប្រម៉ា"។

អត្ថបទសង្ខេបនេះគឺតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកស្ទួយ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងប្រទេសកម្ពុជា។ នេះជាអត្ថបទសង្ខេបមួយលើ "ការវិភាគផ្លូវច្បាប់ នៃការចោទប្រកាន់ និងការផ្តន្ទាទោសទៅលើអ្នកសារព័ត៌មាន និងសកម្មជនការពារសិទ្ធិមនុស្សគឺលោក ម៉ម សូណង់ដូ" ("ការវិភាគផ្លូវច្បាប់") ក៏បានចេញផ្សាយផងដែរដោយ ម.ស.ម.ក នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៣ ហើយបានធ្វើឡើងជាឯកសារយោងបន្ទាន់មួយចំពោះអត្ថបទវិភាគផ្លូវច្បាប់ពេញលេញ ដែលរួមបញ្ចូលជាសំខាន់នូវផ្នែកតូចៗនៃអង្គហេតុ និងការវិភាគលើបទចោទប្រកាន់យ៉ាងពិស្តារ។ ម្យ៉ាងវិញទៀត ដើម្បីជាការពន្យល់ដ៏សង្ខេប និងច្បាស់លាស់ ឯកសារសង្ខេបនេះ ពុំមានដាក់អាគតដ្ឋាននោះទេ ដែលនឹងអាចស្វែងរកបាននៅក្នុងការវិភាគផ្លូវច្បាប់។

ការវិភាគផ្លូវច្បាប់នេះរួមមាន៖ (១) ផ្តល់នូវសាវតារច្បាស់លាស់លើការចាប់ខ្លួន ការចោទប្រកាន់ និងការផ្តន្ទាទោសលើជនជាប់ចោទ ក៏ដូចជា ការប៉ុនប៉ងបង្កើតតំបន់អបគមន៍ដែលបានចោទប្រកាន់ និងឧបទ្ទវហេតុនៅភូមិប្រម៉ា (២) ផ្តល់នូវទិដ្ឋភាពទូទៅផ្នែកសិទ្ធិមនុស្សជាមូលដ្ឋាន ដែលបានត្រូវធ្វើឲ្យប៉ះពាល់ដោយសារតែបទចោទប្រកាន់ ពោលគឺសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិសេរីភាព (ក៏ដូចជាសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស) ហើយធ្វើឲ្យសិទ្ធិទាំងនេះត្រូវបានរំលោភបំពានទាំងស្រុងទៅលើជនជាប់ចោទ (៣) ធ្វើវិភាគជាជំហានៗលើបទចោទប្រកាន់ ដោយធ្វើការពិនិត្យលើការចោទប្រកាន់នីមួយៗជាបន្តបន្ទាប់ និងការលើកយកច្បាប់មកសម្អាងលើអង្គហេតុដូចដែលត្រូវបានរាយការណ៍ ដែលផ្តល់ជាទឡ្ហីករណ៍ថាច្បាប់មិនត្រូវបានគេអនុវត្តបានត្រឹមត្រូវសម្រាប់ផ្នែកភាគច្រើន (៤) ពិនិត្យនូវដំណើរការផ្លូវច្បាប់ទាំងនៅមុនការជំនុំជម្រះ និងខណៈពេលនៃការជំនុំជម្រះនៅសាលាដំបូង ហើយដែលរកឃើញថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានបំពារបំពានតាមប្រការសំខាន់ៗជាច្រើន

និង(៥)សន្និដ្ឋានថាការផ្ដន្ទាទោសទៅលើជនជាប់ចោទ បង្ហាញពីការវិនិច្ឆ័យពុំត្រឹមត្រូវទាំងស្រុងរបស់តុលាការ ហើយហេតុដូច្នេះ មានមូលដ្ឋានច្បាស់លាស់ រឹងមាំ និងមានភាពប្រាកដសម្រាប់ប្ដឹងឧទ្ធរណ៍។

## ២. ច្បាប់

### សេរីភាពជាមូលដ្ឋាន

ការពិចារណាលើ (១) កង្វះភស្តុតាងក្នុងការភ្ជាប់ជនជាប់ចោទទៅនឹងការបង្កើតតំបន់អបគមន៍ ឬឧបទ្ទវហេតុនៅភូមិប្រម៉ា (ដូចបានបង្ហាញនៅក្នុងផ្នែកនៃបទចោទប្រកាន់ និងភស្តុតាងនៅផ្នែកខាងក្រោម) (២) ការកំណត់ពេលវេលាលើសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន (សូមមើលឧបសម្ព័ន្ធ) (៣) តួនាទីរបស់វិទ្យុសំបុកឃ្មុំនៅក្នុងបរិបទនៃបរិយាកាសក្នុងការត្រួតពិនិត្យ និងការរឹតត្បិតសង្គមស៊ីវិល និង(៤) ហេតុដែលថា ជបជាប់ចោទត្រូវបានកំណត់ជាមុខសញ្ញានាពេលកន្លងមក ចំពោះការផ្សព្វផ្សាយវិទ្យុរបស់គាត់ ម.ស.ម.ក ជឿជាក់ថា ជនជាប់ចោទត្រូវបានកំណត់ជាមុខសញ្ញាជាថ្មីក្នុងកាលៈទេសៈនេះ ដោយសារតែការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាមូលដ្ឋានរបស់ខ្លួន។ បន្ថែមលើនេះទៀត ម.ស.ម.ក ផ្ដល់នូវទឡ្ហីករណ៍ថាជនជាប់ចោទត្រូវបានកំណត់ជាមុខសញ្ញា សម្រាប់ការអនុវត្តសិទ្ធិសេរីភាពជាមូលដ្ឋានខាងការបញ្ចេញ–មតិ និងសិទ្ធិក្នុងការបង្កើតសមាគម នៅក្នុងជំនួបជាមួយនឹងអ្នកភូមិជាច្រើននាក់ ព្រមទាំងមេខ្លោងពីររូបនៃតំបន់អបគមន៍ដែលបានចោទប្រកាន់ ("មេខ្លោង") នៅឯគេហដ្ឋានរបស់ជនជាប់ចោទនៅរាជធានីភ្នំពេញ ("កិច្ចប្រជុំកាលពីខែកុម្ភៈ") ហើយដែលបានចូលរួមក្នុងសន្និសីទ ដែលរៀបចំឡើងដោយចលនាអំណាចប្រជាពលរដ្ឋខ្មែរ ("ច.អ.ព.ខ") សម្រាប់ចុងបញ្ចប់នៃកិច្ចការសារព័ត៌មាន និងការរក្សានូវទំនាក់ទំនងជាមួយមេដឹកនាំ ច.អ.ព.ខ គឺលោក សួន សេរីរដ្ឋា។ ម្យ៉ាងទៀត ជនជាប់ចោទ ត្រូវបានចោទពីបទឧក្រិដ្ឋ ដោយគ្រាន់តែហេតុថា លោក ប៊ុន រដ្ឋា ដែលបុគ្គលម្នាក់នៃមេខ្លោងគឺជាអតីតសមាជិកមួយរូបរបស់សមាគមអ្នកប្រជាធិបតេ–យ្យ ដែលប្រការទាំងនេះ បន្ថែមលើការរំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមរបស់ជនជាប់ចោទ។ សេរីភាពជាមូលដ្ឋានទាំងនេះ គឺត្រូវបានការពារទាំងក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដូចមានរៀបរាប់ដូចខាងក្រោម។

មាត្រា៤១នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ខណៈដែលមាត្រា៤២ ការពារនូវសិទ្ធិបង្កើតសមាគម។ មាត្រា៣១ ចែងថា ប្រទេសកម្ពុជា ទទួលស្គាល់ និងគោរពតាមសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស("ស.ស.ស.ម") ព្រមទាំងកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស រួមទាំងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ ម្យ៉ាងវិញទៀត ក.អ.ស.ព.ន ត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់ជាតិ តាមរយៈការផ្ដល់សច្ចាប័នពីកម្ពុជាក្នុងឆ្នាំ១៩៩២ ដោយជាមួយគ្នានឹងការដាក់បញ្ចូលដែលបានបញ្ជាក់តាមរយៈសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលចែងថា *"អនុសញ្ញាអន្តរជាតិទាំងឡាយដែលកម្ពុជាបានទទួលស្គាល់ហើយ* បង្កើតបានជាផ្នែកនៃច្បាប់កម្ពុជា។ មាត្រា

១៩ នៃ ស.ស.ស.ម និង ក.អ.ស.ព.ន ចែងពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋគ្រប់រូប ខណៈដែលមាត្រា២០ នៃ ស.ស.ស.ម និងមាត្រា២២ នៃ ក.អ.ស.ព.ន ការពារសិទ្ធិសេរីភាពនៃការបង្កើតសមាគម។

**សិទ្ធិមានសេរីភាព និងសេរីភាពរួចផុតពីការចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្ត**

ហេតុដែលជនជាប់ចោទត្រូវបានឃុំខ្លួនអស់រយៈពេលជិតបីខែមុនពេលមានការជំនុំជម្រះ (និងចាប់ពីការជំនុំជម្រះ ដែលជាផ្នែកមួយនៃការផ្តន្ទាទោសដាក់ពន្ធនាគារ២០ឆ្នាំ) ក៏ជាការរំលោភលើសិទ្ធិមានសេរីភាពរបស់លោកផងដែរ។ សិទ្ធិមានសេរីភាព និងសេរីភាពរួចផុតពីការចាប់ខ្លួន ឬការឃុំខ្លួនតាមអំពើចិត្ត ត្រូវបានធានាតាមមាត្រា៣២ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៩(១) នៃ ក.អ.ស.ព.ន ក៏ដូចជា ត្រូវបានធានាតាមមាត្រា៣ នៃ ស.ស.ស.ម។ ទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិចែងថា នៅពេលជនណាម្នាក់ត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ ការដោះលែងឲ្យមានសេរីភាពរង់ចាំការជំនុំជម្រះគួរតែត្រូវបានពិចារណាជាជម្រើសមិនត្រូវខកខាន ហើយការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចុងក្រោយ។

**សិទ្ធិការពារសិទ្ធិមនុស្ស**

ក្នុងតួនាទីជាប្រធានសមាគមអ្នកប្រជាធិបតេយ្យ ព្រមទាំងជាអ្នកសារព័ត៌មាន និងជាម្ចាស់ស្ថានីយវិទ្យុ ដែលធ្វើការចែងចាយនូវព័ត៌មានឯករាជ្យទៅកាន់ប្រជាពលរដ្ឋកម្ពុជា ជនជាប់ចោទបានប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីការពារសិទ្ធិមនុស្ស។ គាត់បានការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងជីវភាពនយោបាយនៃប្រទេសរបស់ខ្លួន ហើយក្នុងឋានៈជាអ្នកសារព័ត៌មាន និងអ្នកផ្សព្វផ្សាយ គាត់បានគាំទ្រសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាចំពោះសេរីភាពសារព័ត៌មាន។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ("អ.ស.ប") ស្តីពីអ្នកការពារសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតរបស់ អ.ស.ប ក្នុងឆ្នាំ១៩៩៨ ទោះជាពុំចងជាកាតព្វកិច្ចគតិយុត្តក្តី គឺត្រូវផ្អែកលើសិទ្ធិ និងគោលការណ៍ជាច្រើន ដែលមាននៅក្នុងលិខិតុបករណ៍អន្តរជាតិផ្សេងៗទៀត ដូចជា ក.អ.ស.ព.ន ដែលត្រូវចងជាប់កាតព្វកិច្ច។

## ៣. បទចោទប្រកាន់ និងភស្តុតាង

ការជំនុំជម្រះបានធ្វើឡើងចាប់ពីថ្ងៃទី១១ ដល់១៤ ខែកញ្ញា ឆ្នាំ២០១២ នៅសាលាដំបូងរាជធានីភ្នំពេញ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ លោកស្រី ចាំង ស៊ីណាត និងចៅក្រម លាង សំណាត់ និងចៅក្រម លឹម ម៉ាការីន បានសម្រេចចេញសាលក្រមផ្តន្ទាទោសជនជាប់ចោទ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២។ គាត់បានត្រូវតុលាការរកឃើញពិរុទ្ធភាពពីបទចោទប្រកាន់ ដែលបទចោទទាំងអស់ស្ថិតក្នុងក្រមព្រហ្មទណ្ឌ មានដូចខាងក្រោម៖

- បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម (មាត្រា២៨)
- បទចូលរួមក្នុងចលនាកុបកម្ម (មាត្រា៤៥៦ និងមាត្រា៤៥៧)
- បទញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនិងអាជ្ញាធរស្របច្បាប់ (មាត្រា៤៦៤)
- បទប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា៥០៤) និង

- បទជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ (មាត្រា៦០៩)

ផ្នែកនេះ មានគោលបំណងវិភាគលើករណីចោទប្រកាន់ឲ្យបានហ្មត់ចត់ យ៉ាងប្រុងប្រយ័ត្ន ដោយសារតែតុលាការពុំបានអនុវត្តឲ្យបានត្រឹមត្រូវយ៉ាងជាក់ស្តែងក្នុងសវនាការលើកដំបូង។ អត្ថបទវិភាគផ្លូវច្បាប់សង្ខេបនេះ នឹងផ្តោតសំខាន់លើមាត្រា២៨ ដោយសារតែបទចោទប្រកាន់ទាំងអស់ផ្សេងទៀត ដែលអាស្រ័យលើមាត្រានេះ ជនជាប់ចោទពីព្រោះជនជាប់ចោទត្រូវបានចោទថា ជាអ្នកញុះញង់នៃបទល្មើសដទៃ ហើយការវិភាគផ្នែកច្បាប់នេះ ពិនិត្យនូវរាល់បទចោទប្រកាន់ទាំងអស់ឲ្យបានកាន់តែលម្អិត។

**<u>មាត្រា២៨៖ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមៈ</u>** មាត្រានេះផ្តល់និយមន័យពាក្យថា "អ្នកផ្តើមគំនិត" គឺជាជនដែល៖

*"(១) ជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។*

*(២) បង្កឲ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអំណាចអាជ្ញា ឬអំណាចរបស់ខ្លួន[...]។"*

តាមមាត្រា២៨ អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ហើយ ប្រសិនបើរកឃើញមានករណីដូច្នោះមែន នោះអ្នកផ្តើមគំនិតត្រូវទទួលទោសដូចនឹងចារីដែរ។ ជនជាប់ចោទត្រូវបានចោទប្រកាន់ និងបានត្រូវរកឃើញពិរុទ្ធភាព ជាអ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋចំនួន៥តាមមាត្រា៤៥៦ មាត្រា៤៥៧ មាត្រា៤៦៤ មាត្រា៥០៤ និងមាត្រា៦០៩។ ដើម្បីវាយតម្លៃ ថាតើជនជាប់ចោទអាចត្រូវបានគេរកឃើញពិរុទ្ធភាព ជាអ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋទាំងនេះឬយ៉ាងណានោះ វាចាំបាច់ក្នុងការពិចារណា ថាតើជនជាប់ចោទបានមានជាប់ទាក់ទងជាមួយនឹងការបង្កើតអបគមន៍នោះឬក៏អត់ ទោះជាការបង្កើតអបគមន៍នោះ គឺជាការព្យាយាមដ៏ពិតប្រាកដដើម្បីបំបែករដ្ឋក្តី។ ដើម្បីសម្រេចដូច្នេះបាននោះ ភស្តុតាងចាំបាច់ដែលត្រូវបានដាក់ដោយតំណាងអយ្យការក្នុងតុលាការនោះ នឹងត្រូវធ្វើការពិភាក្សាគ្នា ដើម្បីពិនិត្យមើលនូវពិរុទ្ធភាពរបស់ជនជាប់ចោទក្រោមបទចោទប្រកាន់នេះ។ ផ្នែកសំខាន់បីនៃភស្តុតាងត្រូវបានបង្កើតឡើងដោយតំណាងអយ្យការដើម្បីដាក់បន្ទុកលើជនជាប់ចោទមានដូចជា៖

**១. កិច្ចប្រជុំខែកុម្ភៈ៖** នៅក្នុងចុងខែមករា ឬដើមខែកុម្ភៈ ឆ្នាំ២០១២ ជនជាប់ចោទត្រូវបានចោទថា បានជួបជាមួយនឹងអ្នកភូមិជាច្រើននាក់ និងដែលគេដឹងថា អ្នកបង្កើតតំបន់អបគមន៍ ("អ្នកចូលរួម") ដែលបានអះអាងថា ពួកគេបានពិភាក្សាពីជម្លោះដីធ្លីក្នុងភូមិប្រម៉ាជាមួយនឹងជនជាប់ចោទ ដែលជាអ្នកបានប្រាប់ពួកគេថា ពួកគេគួរតែកាប់ឆ្ការយកដីដើម្បីធ្វើកសិកម្ម ហើយប្រសិនបើពួកគេប្រឈមនឹងបញ្ហា នោះគាត់នឹងជួយ។ នៅខណៈនោះដែរ ជនជាប់ចោទក៏បានទទួលស្គាល់ថា កិច្ចប្រជុំក្នុងខែកុម្ភៈនោះ បានកើតឡើងមែន ហើយបានពន្យល់ថា សមាគមអ្នកប្រជាធិតេយ្យពេលខ្លះជួយដោះស្រាយជម្លោះដីធ្លីតាមមធ្យោបាយសន្តិភាព និងផ្លូវច្បាប់ ហើយលោកបានអះអាងថា លោកមិនបានផ្តល់នូវការជួយជ្រោមជ្រែងណាមួយនោះទេ ផ្ទុយទៅវិញពួកគេបាននិយាយពីការនាំយកភ្លើងអគ្គិសនីចូលទៅកាន់ភូមិប្រម៉ា។ ដោយពុំមានកំណត់ហេតុនៃកិច្ចប្រជុំក្នុងខែកុម្ភៈនោះ ដើម្បីបញ្ជាក់ឲ្យច្បាស់ថា អ្នកចូលរួមនោះពិតជានិយាយការពិត វានៅតែមានផលលំបាកដើម្បីបញ្ជាក់ពីអ្វីដែល

ពួកគេបានពិភាក្សាគ្នា។ ដូច្នេះហើយ ភស្តុតាងរបស់ព្រះរាជអាជ្ញាក្នុងចំណុចនេះ នៅតែស្ថិតក្នុងការជជែកគ្នា ហើយពុំអាចសម្អាងថា ជាភស្តុតាងដាក់បន្ទុកនៃការញុះញង់ឲ្យបង្កើតតំបន់អបគមន៍របស់ជនជាប់ចោទនោះឡើយ។

**២. សមាគមអ្នកប្រជាធិបតេយ្យ៖** ព្រះរាជអាជ្ញាបានអះអាងថា ប៊ុន រដ្ឋា គឺជាសមាជិកនាពេលបច្ចុប្បន្នមួយរូបរបស់សមាគមអ្នកប្រជាធិបតេយ្យ ហើយថាលោកបានក្រវីនិមិត្តសញ្ញារបស់សមាគមអ្នក ប្រជាធិបតេយ្យ និងរូបថតរបស់ជនជាប់ចោទទៀតផងនៅឯកិច្ចប្រជុំ ស្របពេលដែលធ្វើការលើកទឹកចិត្ត ជំរុញ និងជួនកាលដាក់សម្ពាធអ្នកផ្សេងទៀតឲ្យក្លាយជាសមាជិករបស់សមាគមនោះ។ យ៉ាងណាក្តី បើទោះជាការបង្កើតតំបន់អបគមន៍ពិតជាបានបង្ហាញថា ជាការប៉ុនប៉ងមួយដ៏ពិតប្រាកដក្តី មេខ្លោងទំនងជាបានប្រើប្រាស់សមាគមអ្នកប្រជាធិបតេយ្យក្នុងការភ្ជាប់ទៅនឹងផលប្រយោជន៍របស់ពួកគេ ដោយពុំមានការអនុញ្ញាត ឬទទួលស្គាល់ពីជនជាប់ចោទ។ ពុំមានដំណាក់កាលណាមួយនៅក្នុងការជំនុំជម្រះមានភស្តុតាងពិតប្រាកដ ដែលត្រូវបានបង្ហាញពីទំនាក់ទំនងរវាងសមាគមអ្នកប្រជាធិបតេយ្យ និងសកម្មភាពនានារបស់មេខ្លោងនោះឡើយ មានតែទំនាក់ទំនងតែម្យ៉ាង ដែលនឹងបង្ហាញថាជនជាប់ចោទបានញុះញង់ឲ្យមានការប្រព្រឹត្តបទល្មើសតាមបទចោទប្រកាន់។ ដូច្នេះ ភស្តុតាងរបស់ព្រះរាជអាជ្ញាក្នុងចំណុចនេះ មិនអាចត្រូវសម្អាងឡើង ដើម្បីបង្ហាញថាជនជាប់ចោទមានពិរុទ្ធ–ភាពតាមបទចោទប្រកាន់នោះទេ។

**៣. ទំនាក់ទំនងជាមួយ ច.អ.ព.ខ៖** តំណាងអយ្យការ បានអះអាងថា ដោយសារតែជនជាប់ជនជាប់ចោទមានទំនាក់ទំនងជាមួយលោក សួន សេរីរដ្ឋា និងបានចូលរួមព្រឹត្តិការណ៍របស់ ច.អ.ព.ខ ហើយដោយសារតែជនជាប់ចោទមិនអាចបង្ហាញថាខ្លួនមិនប្រកាន់នូវទស្សនៈដូច សួន សេរីរដ្ឋា និង ច.អ.ព.ខ ទេនោះ គាត់ និងសមាគមអ្នកប្រជាធិបតេយ្យត្រូវចែករំលែកនូវគោលដៅជាមួយនឹង ច.អ.ព.ខ ក្នុងការផ្តួលរលំរាជរដ្ឋាភិបាលកម្ពុជា ("រ.ដ.ក") ដោយសន្តិវិធី។ ពុំមានមូលដ្ឋានផ្នែកច្បាប់ ឬក៏មូលដ្ឋានត្រឹមត្រូវចំពោះការដាក់បន្ទុកនេះ យ៉ាងណាក្តី ទឡ្ហីករណ៍បែបនេះ រំលោភលើគោលការណ៍សច្ចធារណ៍នៃការគ្មានទោស ដែលបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ ជនជាប់ចោទបានអះអាងថា គាត់បានចូលរួមកិច្ចប្រជុំរបស់ ច.អ.ព.ខ ក្នុងគោលបំណងទទួលបានព័ត៌មាន និងបានបំពេញការងារក្នុងក្របខណ្ឌសិទ្ធិរបស់ខ្លួន ដែលគ្មានមធ្យោបាយណាមួយភ្ជាប់រូបគាត់ជាមួយនឹងការបង្កើតតំបន់អបគមន៍នោះឡើយ។ ដូច្នេះ ភស្តុតាងរបស់តំណាងអយ្យការចំពោះចំណុចថា ទំនាក់ទំនងរបស់ជនជាប់ជនជាប់ចោទជាមួយនឹងលោក សួន សេរីរដ្ឋា និង ច.អ.ព.ខ ពុំអាចយកមកជាសម្អាងថា ជាភស្តុតាងនៃការញុះញង់ឲ្យមានចលនាអបគមន៍របស់ជនជាប់ចោទ ក្រោមបទចោទប្រកាន់នេះទេ។

នៅពេលដែលផ្នែកនៃភស្តុតាងទាំងបីនេះ ត្រូវបានពិនិត្យពិចារណាយ៉ាងហ្មត់ចត់វាច្បាស់ណាស់ថាពុំមានមូលដ្ឋានច្បាស់លាស់សម្រាប់សម្អាងថាជនជាប់ចោទបានផ្តល់នូវការណែនាំ ឬបញ្ជា ឬបានបង្កឲ្យការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះឡើយ។ គ្មានភស្តុតាងត្រូវបានបង្ហាញដោយតំណាងអយ្យការ ដើម្បីបង្ហាញថាលោកធ្លាប់បានទៅទស្សនៈកិច្ចនៅភូមិប្រម៉ា ឬថាលោកធ្លាប់មានទំនាក់ទំនងជាមួយក្រុមមេខ្លោង ក្រៅតែពីកិច្ច

ប្រជុំក្នុងខែកុម្ភៈ។ ជាការពិត លោកមិនបានស្ថិតនៅក្នុងប្រទេសកម្ពុជាទេ នៅពេលមានចលនាអបគមន៍នោះ ដោយលោក បានស្ថិតនៅក្រៅប្រទេសចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១២ ជាពេលដែលលោកបានត្រឡប់មកកាន់កម្ពុជាវិញដើម្បីប្រឈមនឹងបទចោទប្រកាន់។ ថ្វីបើកង្វះភស្តុតាងទាំងនេះ ជនជាប់ចោទបានត្រូវរកឃើញថា ជាអ្នកញុះញង់ដូចដែលបានកំណត់នៅក្នុងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូចនេះ គាត់បានទទួលទោសដូចគ្នានឹងមេខ្លោង ចំពោះការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ដូចអ្វីដែលគាត់ត្រូវបានចោទប្រកាន់។

បទចោទប្រកាន់៥ករណីផ្សេងទៀត គឺអាស្រ័យលើសច្ចធារណ៍ ដែលជនជាប់ចោទគឺជា "អ្នកញុះញង់"(តាមមាត្រា២៨) ដែលពុំមានភស្តុតាងជាក់លាក់ត្រូវបានគេធ្វើឡើងនោះទេ ដូចបាន ពិភាក្សាខាងលើ។ ដូច្នេះហើយ ជនជាប់ចោទមិនគួរត្រូវបានគេរកឃើញពីពិរុទ្ធភាពនៃបទចោទប្រកាន់ផ្សេងទៀតនោះទេ។

## ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានទទួលស្គាល់តាម ស.ស.ស.ម (មាត្រា១០) និង ក.អ.ស.ព.ន (មាត្រា១៤) ដែលត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា តាមរយៈការផ្តល់សច្ចាប័នរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ (សូមមើលផ្នែកសេរីភាពជាមូលដ្ឋានខាងលើ)។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក៏ត្រូវបានទទួលស្គាល់ផងដែរតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ។ តាមរយៈការអង្កេតការណ៍ដោយមានការយកចិត្តទុកដាក់លើការជំនុំជម្រះ មានការបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះរបស់ជនជាប់ចោទជាច្រើនមិនត្រូវបានគេគោរពនោះទេ ដូចជាសិទ្ធិរបស់គាត់ក្នុង៖ ការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង សវនាការជាសាធារណៈ ការទទួលបាននូវសិទ្ធិសន្មតជាមុនថា គ្មានទោសមុនពេលរកឃើញពីពិរុទ្ធភាព ការពិនិត្យ ឬឲ្យគេពិនិត្យសាក្សីប្រឆាំងនឹងខ្លួនគាត់និងការទទួលបាននូវសិទ្ធិស្មើភាពគ្នាក្នុងការកោះហៅសាក្សី។

## ៥. សេចក្តីសន្និដ្ឋាន

ម.ស.ម.ក ធ្វើការថ្កោលទោសជាខ្លាំងលើសាលក្រមផ្តន្ទាទោសប្រឆាំងនឹងជនជាប់ចោទ។ ក្នុងរយៈពេលជាង៤ថ្ងៃ នៃការឃ្លាំមើលយ៉ាងយកចិត្តទុកដាក់លើការជំនុំជម្រះនោះ ម.ស.ម.ក មិនបានយល់ថាមានចំណែកតូចណាមួយនៃភស្តុតាងដែលត្រូវបានភ្ជាប់ជនជាប់ចោទទៅនឹងការបង្កើតតំបន់អបគមន៍នោះទេ។ ម្យ៉ាងវិញទៀត ម.ស.ម.ល ពុំបានយល់ថាមានការបង្ហាញគួរឲ្យជឿជាក់ថាការបង្កើតតំបន់អបគមន៍គឺមិនមានមូលហេតុផ្សេងក្រៅតែពីការរៀបចំយ៉ាងល្អ ដើម្បីជាការតវ៉ាប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដោយឧបទ្ទវហេតុនៅភូមិប្រម៉ាគឺជាមួយដែលរឹតតែឃោរឃៅ និងការគាបសង្កត់ចំពោះក្រុមអ្នកតវ៉ាដីធ្លី។ ហេតុដូច្នេះ ម.ស.ម.ក ផ្តល់នូវទឡ្ហីករណ៍ថាបទចោទប្រកាន់គឺពុំមានមូលដ្ឋាន និងប្រឌិតទាំងស្រុង។ កង្វះផ្នែកភស្តុតាង រឿងសមហេតុសមផល ត្រឹមត្រូវ និងតាមផ្លូវច្បាប់ ដែលតុលាការគួរតែបានធ្វើ ដូចដែល ម.ស.ម.ក និងមជ្ឈដ្ឋានជាច្រើនទៀតបានជំរុញជំរុញក្នុងអំឡុងពេលនៃការជំនុំជម្រះ គួរតែលើកលែងការចោទប្រកាន់ដល់ជនជាប់ជនជាប់ចោទលើគ្រប់បទចោទប្រកាន់ និងដោះលែងគាត់ឲ្យមានសេរីភាពជាបន្ទាន់។ ការផ្តន្ទាទោសនេះ បង្ហាញ

ឲ្យឃើញពីសម្រេចយ៉ាងអយុត្តិធម៌ទាំងស្រុង ដោយមានការរំលោភបំពានជាខ្លាំងលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងសិទ្ធិបង្កើតសមាគម សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសិទ្ធិជាមូលដ្ឋានដែលត្រូវបានចាត់ទុកថាជាជនគ្មានទោសរហូតដល់បង្ហាញពីពិរុទ្ធភាព។ ក្នុងនាមជាសកម្មជនការពារសិទ្ធិមនុស្សដ៏លេចធ្លោរបស់ប្រទេសកម្ពុជាមួយរូប ជនជាប់ចោទបានមានប្រសាសន៍ពីពន្ធនាគារយ៉ាងខ្លីបន្ទាប់ពីការចាប់ខ្លួនរូបលោកថា៖ *"បើទោះជាគេដាក់ពន្ធនាគារខ្ញុំក៏ដោយ ក្នុងចិត្តខ្ញុំ មានសេរីភាព......ខ្ញុំពុំបានធ្វើអ្វីខុសច្បាប់នោះទេ ដូច្នេះ ខ្ញុំនឹងមិនលាក់ខ្លួននោះឡើយ"*។

ជាងនេះទៅទៀត ការផ្តន្ទាទោសនេះ ពិតជាពុំសមមាត្រទាំងស្រុងនោះទេ៖ រយៈពេល២០ឆ្នាំ គឺជាក់ស្តែងជាការផ្តន្ទាទោសអស់មួយជីវិតក្នុងប្រទេសជាច្រើន ហើយជាការផ្តន្ទាទោសប្រហារជីវិតតែម្តងសម្រាប់បុរសដែលមានវ័យជាង៧០ឆ្នាំរូបនេះ។ នៅគ្រាដែលកម្ពុជា គួរតែមានការកែប្រែចំពោះការសង្កត់សង្កិនដែលជាការរំលោភបំពានសិទ្ធិមនុស្សកាលពីឆ្នាំមុន តុលាការគឺបានត្រឹមតែនាំមកនូវភាពអាម៉ាស់បន្ថែមទៀតសម្រាប់ប្រទេសជាតិ។ យើងសង្ឃឹមថាតុលាការនឹងគោរពកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន និងពិចារណាលើបទចោទប្រកាន់ព្រមទាំងភស្តុតាង ដូចបានលើកឡើងតាមរយៈអត្ថបទសង្ខេបនេះ និងការវិភាគផ្លូវច្បាប់។ ប្រសិនបើតុលាការអនុវត្តមែននោះ ម.ស.ម.ក រំពឹងថាជនជាប់ចោទនឹងត្រូវបានលើកលែងការចោទប្រកាន់នៅសវនាការនៃបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣នេះ ហើយនឹងត្រូវដោះលែងភ្លាមៗ។ តែបើមិនដូច្នេះទេនោះ វានឹងក្លាយជាប្រផ្នូលដ៏អាក្រក់សម្រាប់ជំនឿទុកចិត្តនៃប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក អ៊ូ វីរៈ តាមទូរសព្ទ៖ +៨៥៥ (០) ១២៤០ ៤០៥១ ឬ អ៊ីម៉េល៖** ouvirak@cchrcambodia.org**ឬ លោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមទូរសព្ទ៖ + (០) ៨៥៥ ៧៨ ៨០ ៩៩ ៦០ ឬ អ៊ីម៉េល៖** robert.finch@cchrcambodia.org។

## ឧបសម្ព័ន្ធ៖ កាលប្បវត្តិនៃព្រឹត្តិការណ៍

| | |
|---|---|
| ១៩៩៦ | ក្រុមហ៊ុន កាសូទីម បានទទួលសម្បទានដីព្រៃ ក្នុងខេត្តក្រចេះ ដែលមានទំហំផ្ទៃដី ១៥.០០០ហិកតានៃដីទាំងនោះស្ថិតនៅក្នុងភូមិប្រម៉ា។ |
| ១០ ខែឧសភា ២០១០ | សមាគមអ្នកប្រជាធិបតេយ្យ ត្រូវបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃដោយជនជាប់ចោទ។ |
| ០២ ខែកុម្ភៈ ២០១១ | ប៊ុន រដ្ឋា ក្លាយជាសមាជិករបស់សមាគមអ្នកប្រជាធិបតេយ្យ។ |
| ១៤ ខែកក្កដា ២០១១ | សមាគមអ្នកប្រជាធិបតេយ្យ បានបង្កើតសាខាមួយក្នុងខេត្តក្រចេះ។ |
| ខែវិច្ឆិកា ២០១១ | ប៊ុន រដ្ឋា បានលាលែងពីសមាគមអ្នកប្រជាធិបតេយ្យ |
| ខែមករា ២០១២ | ចាប់ផ្តើមមានទំនាស់ក្នុងភូមិប្រម៉ា រវាងក្រុមហ៊ុន កាសូទីម និងអ្នកភូមិ |
| ចុងខែមករា / ដើមខែកុម្ភៈ ២០១២ | សមាជិករបស់ក្រុមលោក ប៊ុន រដ្ឋា បានទៅភ្នំពេញ និងបានជួបរយៈពេលខ្លីជាមួយជនជាប់ចោទ តែលោក ប៊ុន រដ្ឋា មិនបានចូលរួមនោះទេ។ |
| ខែកុម្ភៈ ដល់ ខែមេសា ២០១២ | កិច្ចប្រជុំត្រូវបានប្រព្រឹត្តទៅរវាងក្រុមរបស់ ប៊ុន រដ្ឋា និងអ្នកភូមិ។ |
| ១០ ខែមីនា ២០១២ | ប៊ុន រដ្ឋា និងក្រុមរបស់លោក បានផ្លាស់ទៅកាន់ភូមិប្រម៉ា។ |
| ១២ ខែមីនា ២០១២ | ជនជាប់ចោទបានចាកចេញពីប្រទេសកម្ពុជាទៅសហរដ្ឋអាមេរិច ("ស.រ.អា")។ នៅថ្ងៃដដែលនោះ សាខាការិយាល័យរបស់ក្រុមហ៊ុន កាសូទីម បានចោទថាត្រូវបានគេដុ តបន្ទាប់ពីមានការប្រឆាំងតវ៉ា នៅឯការដ្ឋានសំណង់របស់កាសូទីមដោយអ្នកភូមិ ៥០០នាក់។ |
| ១៧/១៨ ខែមីនា ២០១២ | ជនជាប់ចោទបានចូលរួមព្រឹត្តការណ៍ក្នុងតំបន់ លីនវ៉ូដ រដ្ឋវ៉ាស៊ីនតោន ស.រ.អា ជាមួយលោក សួន សេរីរដ្ឋា មេដឹកនាំ ច.អ.ព.ខ ។ |

| | |
|---|---|
| ៣០ ខែមីនា ២០១២ | ជនជាប់ចោទបានចូលរួមព្រឹត្តិការណ៍មួយផ្សេងទៀតរបស់ ច.អ.ព.ឌ ក្នុងស្តុកតុន រដ្ឋកាលីហ្វ៊ូនយ៉ា ស.រ.អា។ |
| ៣១ ខែមីនា ២០១២ | ជនជាប់ចោទបានចូលរួមព្រឹត្តិការណ៍ផ្សេងទៀតរបស់ ច.អ.ព.ឌ នៅហ្វ្រេស្នូ កាលីហ្វ៊ូនយ៉ា ស.រ.អា។ |
| ០៦ ខែមេសា ២០១២ | ប៊ុន រដ្ឋា ត្រូវបានចាប់ខ្លួន និងបានត្រូវចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន នៅថ្ងៃទី១២ ខែមិនា ឆ្នាំ២០១២ ជាប់ពាក់ព័ន្ធទៅនឹងការប៉ុនប៉ងដើម្បីការពារការទាមទារដីធ្លីនៅភូមិប្រម៉ា។ អ្នកភូមិ២០០នាក់បានតវ៉ា និងបិទផ្លូវបន្ទាប់ពី ប៊ុន រដ្ឋា ត្រូវអាជ្ញាធរចាប់ខ្លួន។ |
| ០៩ មេសា ២០១២ | អ្នកភូមិប្រហែល៧០០នាក់បានតវ៉ា និងទាមទារឲ្យអាជ្ញាធរដោះលែងប៊ុន រដ្ឋា។ |
| ១០ មេសា ២០១២ | ប៊ុន រដ្ឋា ត្រូវបានដោះលែង។ |
| ២២ មេសា ២០១២ | ប៊ុន រដ្ឋា និងអ្នកភូមិមួយក្រុមបានឃុំខ្លួនមន្ត្រីពីរនាក់ ដើម្បីស្នើសុំព័ត៌មាន និងបានដោះលែងទៅវិញនៅពេលបន្ទាប់មក។ នៅថ្ងៃដដែលនោះ ពួកគេបានសម្រុកចូលទៅក្នុងប៉ុស្តិ៍នគរបាលឃុំកំពុងដំរី។ ពួកគេបានយកឯកសារប៉ូលីស និងហែកចោលនូវបញ្ជីផ្ទេរកម្មសិទ្ធិបណ្តោះរបស់ប៉ុស្តិ៍នគរបាល។ |
| ៣០ មេសា ២០១២ | ប៊ុន រដ្ឋា បានវាស់វែងដីឲ្យទៅប្រជាពលរដ្ឋ។ |
| ០១ ឧសភា ២០១២ | អភិបាលខេត្តក្រចេះ បានបញ្ជូនរបាយការណ៍ទៅក្រសួងមហាផ្ទៃចំពោះ "ជម្លោះដីធ្លីដំណោះស្រាយ កិច្ចពិភាក្សា" និង "សកម្មភាពអាណាធិបតេយ្យ ដោយក្រុមសមាគមអ្នកប្រជាធិបតេយ្យនៅភូមិប្រម៉ា"។ |
| ០២ ឧសភា ២០១២ | ប៊ុន រដ្ឋា និង អ្នកផ្សេងទៀត បានកសាងរបាំង ប្រកចូលចំនួនបួនទៅកាន់ភូមិប្រម៉ា។ |
| ០៤ឧសភា ២០១២ | ក្រសួងមហាផ្ទៃ អនុញ្ញាតឲ្យអាជ្ញាធរខេត្តក្រចេះ ដោះស្រាយជម្លោះយោងលើច្បាប់ ។ល។ តាមមធ្យោបាយអហិង្សា។ |
| ០៧ ឧសភា ២០១២ | នាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាឲ្យមានការផ្អាកជាបណ្តោះអាសន្នបន្ទាន់លើសម្បទានការផ្តល់ដីសម្បទាន។ |
| ១៥ឧសភា ២០១២ | កងរាជអាវុធហត្ថ និងនគរបាលរាប់រយនាក់ បានបង្កើតនូវការ "ឆ្មក់ចូល"នៅភូមិប្រម៉ា ជាប្រតិបត្តិការបែបយោធា ដោយធ្វើការអះអាងថា ប្រតិបត្តិការនេះគឺធ្វើឡើងតែម្យ៉ាងដើម្បីចាប់ពួកមេខ្លោង។ |
| ១៦ឧសភា ២០១២ | កងកម្លាំងប្រដាប់អាវុធ មានជំនួយពីឧទ្ធម្ភាចក្រយោធា បានឆ្មក់ចូលភូមិប្រម៉ា ជាការប៉ុនប៉ងមួយដើម្បីបណ្តេញចេញអ្នកភូមិរាប់ពាន់គ្រួសាររស់នៅលើតំបន់ដីសម្ប |

| | |
|---|---|
| | ទាន។ ក្មេងស្រី១៤ឆ្នាំ ឈ្មោះហេង ចន្ថា បានត្រូវបាញ់ត្រូវ ហើយក្រោយមកបានស្លាប់ដោយសារតែរបួស។ ប៉ូលីសបានចាប់ខ្លួនបុគ្គលច្រើនរូប បាននិយាយថា ជាអ្នកសមគំនិតជាមួយសមាគមអ្នកប្រជាធិបតេយ្យ។ អាជ្ញាធបានបដិសេធមិនឲ្យអ្នកកាសែត និង អង្គការក្រៅរដ្ឋាភិបាល និងតំណាង អ.ស.ប ចូលទៅកាន់ទីនោះជាច្រើនថ្ងៃ។ |
| ២០ ឧសភា ២០១២ | ជនជាប់ចោទ បានជម្រាបពីកិច្ចប្រជុំមួយនៅ វ៉ើជីនា ស.រ.អាដែលគាត់ខ្លាចថា គាត់នឹងត្រូវបានចាប់ខ្លួននៅពេលត្រឡប់មកកម្ពុជាវិញ។ |
| ០៨ មិថុនា ២០១២ | បុគ្គល៥រូប ក្នុងចំណោម៨រូប បានសារភាពថា ជាប់ពាក់ព័ន្ធក្នុងការបង្កើតអបគមន៍នេះ ត្រូវដោះលែងឲ្យនៅក្រៅឃុំ។ បុរសទាំងនោះ ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តកុបកម្មប្រឆាំងអាជ្ញាធរស្របច្បាប់ ប្រឈមជាប់ពន្ធនាគាររយៈពេលចន្លោះពី៧ឆ្នាំ និង១៥ឆ្នាំ។ |
| ២២ មិថុនា ២០១២ | តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅទីក្រុងឡាអេ ជនជាប់ចោទបានសម្ភាសជាមួយសួន សេរីរដ្ឋា ដែលជាអ្នកបានដាក់ពាក្យបណ្តឹង ចោទប្រកាន់រ.ដ.កពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងចំពោះ វិប្បត្តិ ការរំលោភបំពាននូវសិទ្ធិដីធ្លីនៅប្រទេសកម្ពុជា។ |
| ២៥ មិថុនា ២០១២ | វិទ្យុសំបុកឃ្មុំចាក់ផ្សាយនូវកិច្ចសម្ភាសរបស់ជនជាប់ចោទ ជាមួយលោកសួន សេរីរដ្ឋា។ |
| ២៦ មិថុនា ២០១២ | នាយករដ្ឋមន្ត្រីហ៊ុន សែន អំពាវនាវឲ្យមានការចាប់ខ្លួនជនជាប់ចោទ ក្នុងពេលថ្លែងសុន្ទរកថាសាធារណៈមួយនៅមជ្ឈមណ្ឌលកោះពេជ្រ ដោយថ្លែងថា ជនជាប់ចោទគឺជាអ្នកដឹកនាំឲ្យផែនការផ្តួលរំលំ រ.ដ.កនិងបង្កើតជា រដ្ឋក្នុងរដ្ឋ។ |
| ០២ កក្កដា ២០១២ | ចៅក្រមស៊ើបអង្កេតរបស់តុលាខេត្តក្រចេះ បានចេញដីកាចាប់ខ្លួន ដោយចោទជនជាប់ចោទ ពីបទ ចូលរួមក្នុង "ចលនាកុបកម្ម"។ |
| ០៦ កក្កដា ២០១២ | សមាគមអ្នកប្រជាធិបតេយ្យ បានរៀបចំសន្និសីទសារព័ត៌មាន ដោយបានបដិសេធនូវទំនាក់ទំនងរវាងជនជាប់ចោទ និងលោកប៊ុន រដ្ឋា។ សមាគមអ្នកប្រជាធិបតេយ្យក៏បានថ្លែងថា លោកប៊ុន រដ្ឋា មិនមែនជាសមាជិកសកម្មរបស់អង្គការខ្លួន។ |
| ១២ កក្កដា ២០១២ | ជនជាប់ចោទបានត្រឡប់មកកាន់កម្ពុជាវិញពីដំណើរទៅប្រទេសហូ ឡង់ និង ស.រ.អាដើម្បីឆ្លើយបំភ្លឺការចោទប្រកាន់ប្រឆាំងរូបលោក។ |
| ១៥ កក្កដា ២០១២ | ជនជាប់ចោទ ត្រូវបានចាប់ខ្លួនលើការចោទប្រកាន់ពីការដឹកនាំឲ្យចលនាអបគមន៍នៅខេត្តក្រចេះ និងបានត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយឲ្យនៅក្រៅឃុំ។ |

| | |
|---|---|
| ១៦ កក្កដា ២០១២ | ជនជាប់ចោទ ត្រូវបានចោទប្រកាន់ជាផ្លូវការ តាមមាត្រា ២៨ ៤៥៦ ៤៥៧ ៤៦៤ ៥០៤ និងមាត្រា៦០៩ នៃក្រមព្រហ្មទណ្ឌ។ |
| ១៧ កក្កដា ២០១២ | ប៊ុន រដ្ឋា បានបដិសេធថា ជនជាប់ចោទពុំបានពាក់ព័ន្ធក្នុងជម្លោះដីធ្លីនៅខេត្តក្រចេះទេ ហើយរូបលោកផ្ទាល់បានកាន់តួនាទីជាសមាគមន៍អ្នកប្រជាធិបតេយ្យ។ |
| ២២ កក្កដា ២០១២ | រ.ដ.កបានប្រកាសថា មានអ្នកភូមិ៦នាក់បានសារភាពក្នុងបង្កើតចលនាអបគមន៍។ |
| ១១-១៤កញ្ញា ២០១២ | សវនាការរបស់ជនជាប់ចោទនៅសាលាដំបូងក្រុងភ្នំពេញ។ |
| ០១ តុលា ២០១២ | ជនជាប់ចោទបានត្រូវតុលាការរកឃើញពិរុទ្ធភាពនៃបទចោទ តាមមាត្រា ២៨ មាត្រា៤៥៦ មាត្រា៤៥៧ មាត្រា៤៦៤ មាត្រា៥០៤ និងមាត្រា៦០៩ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈ២០ឆ្នាំ និងពិន័យជាប្រាក់១០លានរៀល។ លោក ប៊ុន រដ្ឋា ត្រូវផ្តន្ទាទោសកំបាំងមុខឲ្យជាប់ពន្ធនាគាររយៈពេល ៣០ឆ្នាំ។ |
| ១២ តុលា ២០១២ | ជនជាប់ចោទបានដាក់ពាក្យប្តឹងទាស់ទៅនឹងសាលក្រមសាលាដំបូងរាជធានីភ្នំពេញ។ |
| ១៨ តុលា ២០១២ | សាលាដំបូងរាជធានីភ្នំពេញបានទទួលបណ្តឹងទាស់នោះ។ |
| ១៩ វិច្ឆិកា ២០១២ | លោកប្រធានាធិបតេយ្យ ស.រ.អា បារ៉ាក់ អូបាម៉ា ជំរុញឲ្យនាយករដ្ឋមន្ត្រីហ៊ុន សែន ដោះលែងជនជាប់ចោទ និងអ្នកទោសនយោបាយទាំងអស់។ |
| ២២ វិច្ឆិកា ២០១២ | សំណុំរឿងរបស់ជនជាប់ចោទបានត្រូវបង្វែរទៅសាលាឧទ្ធរណ៍។ |
| ១៣ ធ្នូ ២០១២ | ជនជាប់ចោទត្រូវបានបដិសេធសំណើសុំនៅក្រៅឃុំ មុនពេលសវនាការឧទ្ធរណ៍។ |
| ១៧ កុម្ភៈ ២០១៣ | កាលបរិច្ឆេទត្រូវបានកំណត់សម្រាប់សវនាការឧទ្ធរណ៍ គឺនៅថ្ងៃទី៥ មិនា ឆ្នាំ ២០១៣។ |
| ០៥ មិនា ២០១៣ | សវនាការឧទ្ធរណ៍របស់ជនជាប់ចោទមកដល់។ |

អត្ថបទជាភាសាខ្មែរទាំងមូលនឹងត្រូវបានបញ្ចូលក្នុងពេលឆាប់ៗនេះ